# រឿងព្រានសន្ទូច

( ចាក ធ. ខុ.)

( មិនល្អដោយឈ្មោះទេ លុះតែត្រាស់ដឹងធម៌ទើបល្អ )

សេចក្តី ដំណាលថា ក្នុងក្រុងសាវត្ថី មានព្រានសន្ទូចម្នាក់ឈ្មោះអរិយៈ ។ ថ្ងៃមួយ ព្រាននោះយកសន្ទូចទៅស្ទូចត្រី ក៏បានជួបព្រះសាស្តា មានភិក្ខុសង្ឃចោមរោម ជាបរិវារ-- ត្រាច់បិណ្ឌបាត្រនាស្រុកខាងជើងក្រុងសាវត្ថី ហើយដាក់ដងសន្ទូច ឈរទ្រឹងក្នុងទីនោះ ។ ព្រះសាស្តាស្តេចប្រថាប់ក្បែរព្រាននោះ ត្រាស់សួរព្រះ ថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមថា អ្នកឈ្មោះអ្វី ? ព្រះថេរៈក៏ក្រាបទូល ព្រះនាមរៀងៗខ្លួន ថាខ្ញុំម្ចាស់ឈ្មោះ សារីបុត្រ ខ្ញុំម្ចាស់ឈ្មោះមោគ្គល្លាន ។ ព្រាន សន្ទូចគិតថា ព្រះសាស្តាសួរឈ្មោះសាវៈទាំងឡាយហើយនឹងសួរឈ្មោះអញ ទៀតមិនខាន ។

ព្រះសាស្តាដឹងចិត្តព្រានហើយក៏សួរថា នែឧបាសកឯងឈ្មោះអ្វី ? បពិត្រព្រះអង្គ ដ៏ចំរើន ខ្ញុំឈ្មោះអរិយៈ ។ លំដាប់នោះព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលឧបាសក ជនដែលសម្លាប់សត្វទាំងឡាយ មិនឈ្មោះថាអរិយៈទេ ឯ ព្រះអរិយៈទាំងឡាយ លោកមិនដែលបៀតបៀនសត្វឡើយ ទើបត្រាស់សំដែង គាថា ៖

**នតេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**
**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ**

អ្នកបៀតបៀនពួកសត្វដោយហេតុណា មិនឈ្មោះថា អរិយៈ ដោយហេតុនោះ បណ្ឌិតហៅអរិយៈដោយចំពោះបុគ្គលដែលអត់បៀតបៀនសត្វ ។ ចប់ធម៌ ទេសនាហើយ ព្រានសន្ទូច ក៏បានសម្រេចធម៌ជាន់ខ្ពស់ឈ្មោះសោត ក្នុងពេល នោះ ។

សូមអស់លោកអ្នកអនុមោទនា !

ចប់